01054167

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 13 / 01 / 2015
ម៉ោង (Time/Heure): 11:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E334

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៥

**ជូនចំពោះ៖** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី៖** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖** **លោក/លោកស្រីចៅក្រម, មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ការិយាល័យរដ្ឋបាល**

**កម្មវត្ថុ៖** **សំណើសុំឲ្យសាក្សីដែលមានអក្សរនាម 2-TCW-923 (Richard Dudman) ផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍**

១. អង្គជំនុំជម្រះបានទទួលសំណើពីក្រុមមេធាវីការពារក្តី នួន ជា សុំឲ្យអង្គជំនុំជម្រះពន្លឿនការរៀបចំសវនាការស្តាប់សក្ខីកម្ម **Richard Dudman** ដោយផ្អែកលើមូលហេតុវ័យរបស់គាត់ (គាត់មានអាយុ ៩៦ ឆ្នាំ) ហើយបើចាំបាច់ សុំឲ្យស្តាប់សក្ខីកម្មរបស់គាត់តាមរយៈប្រព័ន្ធសោតទស្សន៍។ សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី មិនបានជំទាស់ទៅនឹងសំណើសុំឲ្យពន្លឿនការស្តាប់សក្ខីកម្មរបស់លោក **Richard Dudman** ឬការស្តាប់សក្ខីកម្មរបស់គាត់តាមរយៈប្រព័ន្ធសោតទស្សន៍នោះទេ (ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ ទំព័រ ៤៦, ៥១, ៥៤ (ភាសាអង់គ្លេស))។ មេធាវីការពារក្តី ខៀវ សំផន មិនបានធ្វើការឆ្លើយតបទៅនឹងសំណើសុំរបស់មេធាវីការពារក្តី នួន ជា ទេ។

២. វិធាន ២៦ នៃវិធានផ្ទៃក្នុង ចែងថា សក្ខីកម្មរបស់សាក្សី ឬអ្នកជំនាញនៅក្នុងអំឡុងពេលជំនុំជម្រះត្រូវធ្វើឡើងដោយមានវត្តមានរបស់បុគ្គលនោះដោយផ្ទាល់ នៅពេលណាដែលអាចធ្វើទៅបាន។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះអាចអនុញ្ញាតឲ្យសាក្សីធ្វើសក្ខីកម្ម

តាមរយៈបច្ចេកវិទ្យាសោតទស្សន៍ ឬទូរទស្សន៍ ក្នុងករណីដែលបច្ចេកវិទ្យាបែបនេះអនុញ្ញាតឱ្យអង្គជំនុំជម្រះ និងភាគីសាកសួរសាក្សីបាន ក្នុងអំឡុងពេលដែលសាក្សីនោះផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ (វិធាន ២៦ (១) នៃវិធានផ្ទៃក្នុង)។

៣. សេចក្តីសម្រេចអំពីថាតើត្រូវអនុញ្ញាតឱ្យផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ ឬមិនអនុញ្ញាតនោះ គឺជាបញ្ហាមួយដែលស្ថិតនៅក្រោមឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង។ ប្រសិនបើមានសំណើសុំឱ្យអនុវត្តវិធានការពិសេសផ្សេងៗនោះ អង្គជំនុំជម្រះត្រូវវាយតម្លៃពីតម្រូវការរបស់បុគ្គលដែលត្រូវផ្តល់សក្ខីកម្មនោះ។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចពីមុនមកថា សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍អាចនឹងត្រូវបានអនុញ្ញាត ក្នុងករណីដែលកាលៈទេសៈតម្រូវឱ្យធ្វើបែបនេះ (ឯកសារ E166/1/4) ហើយអង្គជំនុំជម្រះធ្លាប់បានអនុញ្ញាតឱ្យមានការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍នៅពេលដែលបញ្ហាសុខភាពធ្វើឱ្យសាក្សីមិនអាចធ្វើដំណើរមកផ្តល់សក្ខីកម្មដោយផ្ទាល់បាន (ឯកសារ E1/151, E236/1/4/3)។

៤. នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងទៅភាគី តាមរយៈមន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនថា អង្គជំនុំជម្រះកំពុងព្យាយាមទាក់ទងទៅលោក **Richard Dudman** ដើម្បីបញ្ជាក់អំពីវត្តមានរបស់គាត់។ បច្ចុប្បន្ននេះ លោក **Richard Dudman** បានបញ្ជាក់អំពីវត្តមានរបស់គាត់ក្នុងការផ្តល់សក្ខីកម្មហើយ ប៉ុន្តែគាត់បានបញ្ជាក់ថា គាត់អាចផ្តល់សក្ខីកម្មតែតាមរយៈប្រព័ន្ធសោតទស្សន៍ប៉ុណ្ណោះ។ អង្គជំនុំជម្រះបានទទួលឯកសារវេជ្ជសាស្ត្រមួយពីវេជ្ជបណ្ឌិត Sufana Alkhunaizi ដែលលើកឡើងថា ការធ្វើដំណើរមកប្រទេសកម្ពុជាដើម្បីផ្តល់សក្ខីកម្មអាចបង្កគ្រោះថ្នាក់ដល់លោក **Richard Dudman** ដោយសារតែអាយុ និងស្ថានភាពសុខភាពរបស់គាត់ (ឯកសារ E334.1)។

៥. គ្មានភាគីណាមួយបានជំទាស់ថា ការស្តាប់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍នៅក្នុងកាលៈទេសៈបែបនេះ នាំឱ្យប៉ះពាល់ធ្ងន់ធ្ងរ ឬរំលោភសិទ្ធិរបស់ជនជាប់ចោទនោះទេ (វិធាន ២៦(១) នៃវិធានផ្ទៃក្នុង)។

៦. ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ជាការសមស្របដែលត្រូវរៀបចំសវនាការស្តាប់សក្ខីកម្មរបស់លោក **Richard Dudman** តាមរយៈប្រព័ន្ធសោតទស្សន៍ នៅក្នុងដំណាក់កាលដំបូងនៃការជំនុំជម្រះនេះ ហើយស្នើឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ធ្វើការចាត់ចែងចាំបាច់គ្រប់យ៉ាងជាមួយនឹងអាជ្ញាធរពាក់ព័ន្ធ ដើម្បីអាចឱ្យលោក **Richard Dudman** ផ្តល់សក្ខីកម្មនៅក្នុងសប្តាហ៍ទីមួយនៃខែ កុម្ភៈ ឆ្នាំ ២០១៥។

៧. ដោយសារតែពេលវេលាខុសគ្នា (១២ ម៉ោង) អាយុ និងការស្នើសុំរបស់សាក្សី អង្គជំនុំជម្រះនឹងរៀបចំសវនាការស្តាប់សក្ខីកម្មរបស់សាក្សីរូបនេះចាប់ពីម៉ោង ៨ ដល់ម៉ោង ១០ ព្រឹក នៅបន្ទប់សវនាការ។ នៅក្នុងថ្ងៃនីមួយៗ បន្ទាប់ពីស្តាប់សក្ខីកម្មរបស់លោក **Richard Dudman** រួច អង្គជំនុំជម្រះនឹងឈប់សម្រាករយៈពេលខ្លី ហើយបន្ទាប់មក នឹងបន្តធ្វើសវនាការដើម្បីស្តាប់សក្ខីកម្មរបស់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត រហូតដល់ម៉ោង ៣ រសៀល។ ការឈប់សម្រាកសម្រាប់អាហារថ្ងៃត្រង់នឹងចាប់ផ្តើមពីម៉ោង ១២:០០ រហូតដល់ម៉ោង ១:៣០ នាទីរសៀល។